ធ៧-០១-១៨៦ ប្រ.ក

# ប្រកាស
# ស្ដីពី
# អចលនទ្រព្យរបស់ធនាគារ

**ប្រការ ១**.-

កម្មសិទ្ធិលើអចលនទ្រព្យរបស់គ្រឹះស្ថានធនាគារត្រូវបញ្ញត្តិតាមខ្លឹមសារនៃប្រកាសនេះ។

**ប្រការ ២**.-

គ្រឹះស្ថានធនាគារអាចទទួលយកអចលនទ្រព្យបានតែក្នុងករណីពីរ ៖

- អចលនទ្រព្យទាំងនោះត្រូវបានប្រើប្រាស់ដោយផ្ទាល់សម្រាប់ប្រតិបត្តិការធនាគារ
- អចលនទ្រព្យមិនបានប្រើប្រាស់សម្រាប់ប្រតិបត្តិការធនាគារនោះ ប៉ុន្តែអចលនទ្រព្យទាំងនោះបានក្លាយជាទ្រព្យសម្បត្តិរបស់ធនាគារ ដោយការរឹបអូសតាមច្បាប់ និងជួយកាត់បន្ថយហានិភ័យលើបំណុលអាក្រក់។

**ប្រការ ៣**.-

អចលនទ្រព្យដែលធ្វើលទ្ធកម្មដោយធនាគារសម្រាប់គោលដៅប្រតិបត្តិការ ត្រូវតែរក្សាមិនឱ្យលើសពី៣០% នៃមូលនិធិផ្ទាល់សុទ្ធសរុប ដូចមានកំណត់ក្នុងប្រកាសលេខ ធ៧-០១០-១៨២ ប្រក។

**ប្រការ ៤**.-

អចលនទ្រព្យដែលគ្មានទំនាក់ទំនងផ្ទាល់ជាមួយប្រតិបត្តិការធនាគារ ត្រូវលក់ចេញមិនឱ្យលើសពីមួយឆ្នាំ ក្រោយកាលបរិច្ឆេទដែលអចលនទ្រព្យបានក្លាយជាទ្រព្យសម្បត្តិរបស់ធនាគារ ហើយអចលនទ្រព្យទាំងនោះត្រូវកត់ត្រាក្នុងបញ្ជីគណនីរបស់ធនាគារតាមតម្លៃជាក់ស្ដែងសមស្រប។

**ប្រការ ៥**.-

ការរំលោភលើបញ្ញត្តិនៃប្រកាសនេះ នឹងត្រូវទទួលរងការពិន័យ និងទណ្ឌកម្មដូចដែលមានចែងនៅត្រង់មាត្រា ៥២ នៃច្បាប់ស្ដីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៦**.-

ធនាគារត្រូវរាយការណ៍ប្រចាំខែមកធនាគារជាតិនៃកម្ពុជា ពីការអនុវត្តន៍ស្របតាមខ្លឹមសារនៃប្រកាសនេះ តាមគំរូដែលកំណត់ដោយសារាចរណែនាំ។

**ប្រការ ៧**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៨**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**